# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ៥ ចេញផ្សាយថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

Issue 5 : 22 / 6 / 2023


## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

# គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពី ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ តាមមណ្ឌលរាជធានី ខេត្ត

នាព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)





ឯកឧត្តម ឌុច សុន សមាជិក គ.ជ.ប

តទៅទំព័រទី២

**មាតិកា៖** **ទំព័រ**


- គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពី ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ ..............១
- លទ្ធផលបណ្តោះអាសន្ននៃការចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សម្រាប់ចូលរួមយកព័ត៌មាន ...................៤
- វគ្គបណ្តុះបណ្តាលជូនមន្ត្រី គ.ជ.ប និងភាគីពាក់ព័ន្ធ ស្តីពី "ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល ...៧
- គណបក្សនយោបាយ ត្រូវមានឱកាសស្មើភាពគ្នាក្នុងការផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួនតាមប្រព័ន្ធផ្សព្វផ្សាយ ..១០
- គ.ជ.ប អំពាវនាវឱ្យបញ្ឈប់សកម្មភាពឃោសនាក្នុងចេតនាមិនឱ្យប្រជាពលរដ្ឋទៅបោះឆ្នោត ឬឱ្យគូសសន្លឹកឆ្នោត .......១២
- គ.ជ.ប នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមការងារក្នុងក្របខណ្ឌបោះឆ្នោត នៃប្រទេសនិយាយភាសាបារាំង .............១៣
- គ.ជ.ប រៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ...........១៥

តមកពីទំព័រទី១ គ.ជ.ប រៀបចំកិច្ចប្រជុំ ...

មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាព ឯកឧត្តម **ឌុច សុន** សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការតាមមណ្ឌលរាជធានី ខេត្ត ទាំង ២៥ សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន និងការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។

ឯកឧត្តម **ឌុច សុន** បានមានប្រសាសន៍ថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងតាមប្រព័ន្ធសមាមាត្រ ដោយយករាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោត។ អាសនៈនៅក្នុងរដ្ឋសភា



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

មានចំនួន ១២៥ (មួយរយម្ភៃប្រាំ) ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ហើយឯកឧត្តមក៏បានរំលឹកអំពីដំណើរការនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះដែលទើបតែបញ្ចប់ទៅ ដោយមានគណបក្សនយោបាយ ចំនួន ១៨ ត្រូវបានទទួលស្គាល់ជាផ្លូវការក្នុងការចូល-រួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ឯកឧត្តម **ឌុច សុន** បានមានប្រសាសន៍បន្តថា បន្ទាប់ពីបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេលដែលបណ្តឹងតវ៉ាត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរ គ.ជ.ប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន



គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ឈរឈ្មោះតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត របស់គណបក្សនយោបាយទាំងនោះ ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ព្រមទាំងបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប។ តាមកាលបរិច្ឆេទកំណត់របស់ គ.ជ.ប បញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបិទផ្សាយជាសាធារណៈនៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តទាំង ២៥ ចាប់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ដោយត្រូវបិទផ្សាយនៅលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ចំនួន ១ (មួយ) ច្បាប់ និងនៅទីប្រជុំជនធំៗមួយចំនួនក្នុងរាជធានី ខេត្តនីមួយៗ។

ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការការពារសុវត្ថិភាពរបស់បេក្ខជន ឯកឧត្តម **ឌុច សុន** បានថ្លែងថា បេក្ខជនគ្រប់រូប និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ ទទួលបានសិទ្ធិស្មើគ្នាក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងសម័យបោះឆ្នោត ដូចមានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធី ក្រមសីលធម៌ និងផែនការអន្តរស្ថាប័នរវាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

និង គ.ជ.ប។ ឯកឧត្តមបានបន្តថា ប្រសិនបើបេក្ខជនអាចផ្តល់ភស្តុតាង ឬមានមូលហេតុច្បាស់លាស់ថា សន្តិសុខ និងសុវត្ថិភាពរបស់ខ្លួនត្រូវបាន និងកំពុងរងនូវការគំរាមកំហែងនោះ បេក្ខជនអាចប្តឹងទៅ គ.ជ.ប ជាបន្ទាន់ ដើម្បីឱ្យ គ.ជ.ប ធ្វើការប្រជុំការងារសន្តិសុខ ដើម្បីដោះស្រាយពាក្យបណ្តឹង ដោយបើកការស៊ើបអង្កេត ហើយទន្ទឹមគ្នានេះត្រូវចាត់វិធានការចាំបាច់គ្រប់រូបភាពដើម្បីផ្តល់សន្តិសុខ និងសុវត្ថិភាពជូនបេក្ខជន។ឯកឧត្តមបន្ថែមថា នៅពេលដែលការស៊ើបអង្កេតរកឃើញភស្តុតាងអំពីការគំរាមកំហែងសន្តិសុខ និងសុវត្ថិភាពដល់បេក្ខជនឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវដោះស្រាយតាមច្បាប់ និងនីតិវិធីនៃការបោះឆ្នោត។

ចំពោះការសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ឯកឧត្តម **ឌុច សុន** បានបញ្ជាក់ជូនថា គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្នុងមណ្ឌលរាជធានី ខេត្តណាមួយ មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ចំនួន ១ (មួយ) រូប និងភ្នាក់ងារបម្រុង ចំនួន ១ (មួយ) រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់។ កាលបរិច្ឆេទនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ មានរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គឺចាប់ផ្តើមពីថ្ងៃទី១៤ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣។

ឯកឧត្តម **ឌុច សុន** បានបញ្ជាក់ជូនបន្តទៀតថា បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅគ្រប់ដំណាក់កាល។

ចំពោះពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ឯកឧត្តម **ឌុច សុន** បានជម្រាបជូនថា ត្រូវបំពេញតាមទម្រង់



**សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

បែបបទលេខ ១០០៧ ដែលត្រូវផ្តល់ជូនដោយឥតគិតថ្លៃ ដោយ គ.ជ.ប។ គណបក្សនយោបាយអាចថតចម្លងពាក្យសុំទម្រង់បែបបទលេខ ១០០៧ ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ។ គណបក្សនយោបាយក៏អាចទាញយកទម្រង់បែបបទលេខ ១០០៧ ពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ហើយការផ្ទេរនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរបន្ត។

ជាចុងក្រោយ ឯកឧត្តម **ឌុច សុន** សង្ឃឹមជឿជាក់យ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដោយគោរពតាមច្បាប់ បទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌ ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រប្រព្រឹត្តទៅរលូន មានសន្តិសុខល្អ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។

កិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតនេះ មានការអញ្ជើញចូលរួមពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មន្ត្រីស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា តំណាងគណបក្សនយោបាយ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានចំនួនប្រមាណ ៦០នាក់៕

# លទ្ធផលបណ្ដោះអាសន្ននៃការចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សម្រាប់ចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គិតត្រឹមថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានទទួលស្គាល់ និងផ្ដល់បណ្ណសម្គាល់ជូនអ្នកសារព័ត៌មានជាតិ សរុបចំនួន ៦៣៩ នាក់ ស្ត្រី ចំនួន ១០០ នាក់ មកពី ៥៥ អង្គភាព និងអ្នកសារព័ត៌មានអន្តរជាតិ សរុបចំនួន ៥២ នាក់ ស្ត្រី ចំនួន ៧ នាក់ មកពី ២២ អង្គភាព ដើម្បីចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះអង្គភាព | ផ្ដល់បណ្ណ | |
|---|---|---|---|
| | | សរុប | ស្រី |
| **ក. អ្នកសារព័ត៌មានជាតិ** | | | |
| ១ | កាសែត Khmer Times | ១៥ | - |
| ២ | អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា | ៣២ | |
| ៣ | សំឡេងសហរដ្ឋអាមេរិក (VOA) | ៨ | ៣ |
| ៤ | គេហទំព័រ www.rmn.asia | ១៧ | - |
| ៥ | ស្ថានីយទូរទស្សន៍ CNC | ៣៤ | ២ |
| ៦ | គេហទំព័រ www.knp-news.com | ១ | - |
| ៧ | ស្ថានីយវិទ្យុ និងទូរទស្សន៍ហង្សមាស | ១០ | |
| ៨ | គេហទំព័រ www.anachakkhmer.com | ២ | |
| ៩ | គេហទំព័រ www.cc-times.com | ៩ | ៤ |
| ១០ | អង្គភាពព័ត៌មាន Swift News | ១០ | ៤ |
| ១១ | គេហទំព័រ www.tamaonews.com | ៦ | - |
| ១២ | ស្ថានីយវិទ្យុ និងទូរទស្សន៍ប៉ុស្តិ៍លេខ៣ រាជធានីភ្នំពេញ | ៣ | |
| ១៣ | មន្ទីរព័ត៌មានរាជធានីភ្នំពេញ | ២ | |
| ១៤ | សារព័ត៌មាន រស្មីកម្ពុជា | ១ | |
| ១៥ | ស្ថានីយទូរទស្សន៍ PNN | ២៩ | ៥ |

| | | | |
|---|---|---|---|
| ១៦ | ស្ថានីយទូរទស្សន៍ កម្ពុជាប៉ុស្តិ៍លេខ៨ អេចឌី | ៣ | |
| ១៧ | កាសែត ដានហ្វា | ៥ | - |
| ១៨ | គេហទំព័រ www.khi-newsdaily.com | ២ | |
| ១៩ | អង្គភាពព័ត៌មាន FRESH NEWS | ៣២ | ៤ |
| ២០ | សារព័ត៌មាន កម្ពុជាថ្មី | ១៩ | ៤ |
| ២១ | គេហទំព័រ Cam Post | ១ | - |
| ២២ | គេហទំព័រ www.bdp-news.com | ៤ | ២ |
| ២៣ | គេហទំព័រ www.readnews.tv | ១៧ | |
| ២៤ | គេហទំព័រ www.plpt.net | ១ | - |
| ២៥ | គេហទំព័រ www.kap-news.com | ២ | |
| ២៦ | គេហទំព័រ www.donkeo.net | ៤ | ១ |
| ២៧ | គេហទំព័រ www.bvs-tvonline.net | ៤ | |
| ២៨ | គេហទំព័រ www.bcp-tv.com | ១០ | - |
| ២៩ | សមាគមអ្នកសារព័ត៌មានកម្ពុជាដើម្បីសេរីភាព | ៥ | |
| ៣០ | The Phnom Penh Post | ៨ | ១ |
| ៣១ | គេហទំព័រ www.preahvihear tv.asia | ៣ | - |
| ៣២ | ស្ថានីយវិទ្យុវាយោ | ១៥ | ៥ |
| ៣៣ | គេហទំព័រ www.dap-news.com | ២០ | ១ |
| ៣៤ | កាសែត យុត្តិធម៌ | ១ | |
| ៣៥ | សារព័ត៌មាន រស្មីកម្ពុជា | ២ | - |
| ៣៦ | សារព័ត៌មាន កោះសន្តិភាព | ១ | |
| ៣៧ | គេហទំព័រ www.mlctv-news.com | ១ | |
| ៣៨ | គេហទំព័រ www.speandak.com | ៣ | ១ |
| ៣៩ | គេហទំព័រ www.khmer7news.com | ៣ | - |
| ៤០ | គេហទំព័រ www.nrk.asia | ៣ | ២ |
| ៤១ | គេហទំព័រ www.kohreport.com | ៣ | - |
| ៤២ | គេហទំព័រ www.camasianews.com | ៧ | |

| | | | |
|---|---|---|---|
| ៤៣ | គេហទំព័រ www.tnaot.com | ៦ | ៣ |
| ៤៤ | គេហទំព័រ www.cpnnews.net | ៨ | - |
| ៤៥ | គេហទំព័រ www.nrcmtv.com | ១៩ | ១ |
| ៤៦ | អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា | ១១ | ៣ |
| ៤៧ | គេហទំព័រ www.thmeythmey.com | ៤៤ | ១៩ |
| ៤៨ | ស្ថានីយទូរទស្សន៍-វិទ្យុអាស៊ីអាគ្នេយ៍ | ៧ | - |
| ៤៩ | គេហទំព័រ www.tk-hotnews.com | ៧ | ២ |
| ៥០ | គេហទំព័រ www.khmercm.com | ១ | ១ |
| ៥១ | សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា | ៧ | ១ |
| ៥២ | គេហទំព័រ www.eacnews.asia | ៦ | ២ |
| ៥៣ | ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា | ៤២ | ១០ |
| ៥៤ | អគ្គនាយកដ្ឋានវិទ្យុ និង ទូរទស្សន៍បាយ័ន | ៥៩ | ៧ |
| ៥៥ | អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន | ៦៤ | ១២ |
| **សរុប** | | **៦៣៩** | **១០០** |
| **ខ. អ្នកសារព័ត៌មានអន្តរជាតិ** | | | |
| ១ | កាសែត Khmer Times | ១ | - |
| ២ | សារព័ត៌មាន Thomson Reuter | ១ | |
| ៣ | European Pressphoto Agency ( EPA ) | ១ | |
| ៤ | The Asahi Shimbun | ១ | |
| ៥ | កាសែត Nhan Dan | ២ | |
| ៦ | ទូរទស្សន៍ជប៉ុន NHK TV | ៣ | |
| ៧ | ទីភ្នាក់ងារសារព័ត៌មាន KYODO NEWS | ៣ | |
| ៨ | JPS ( Japan Professional Photographers Society ) | ១ | |
| ៩ | The Associated Press ( AP ) | ៥ | |
| ១០ | ទីភ្នាក់ងារសារព័ត៌មានវៀតណាម ( VNA ) | ៣ | |
| ១១ | GLOBE MEDIA ASIA | ៥ | ២ |
| ១២ | The Yomiuri Shimbun | ១ | - |

| | | | |
|---|---|---|---|
| ១៣ | វិទ្យុមិត្តភាពកម្ពុជាចិន | ៦ | ១ |
| ១៤ | សារព័ត៌មាន កម្ពុជាថ្មី | ២ | ១ |
| ១៥ | Xinhua News Agency | ៣ | - |
| ១៦ | The Sydney Morning Herald | ២ | |
| ១៧ | វិទ្យុវៀតណាម ( VOV ) | ២ | |
| ១៨ | Agence France-Presse ( AFP ) | ១ | |
| ១៩ | គេហទំព័រ www.tk-hotnews.com | ៣ | ២ |
| ២០ | Freelance | ១ | - |
| ២១ | Vietnam Television ( VTV ) | ៣ | |
| ២២ | គេហទំព័រ www.eacnews.asia | ២ | ១ |
| **សរុប** | | **៥២** | **៧** |
| **សរុបរួម** | | **៦៩១** | **១០៧** |

ទន្ទឹមនឹងនេះ គ.ជ.ប កំពុងពិនិត្យលើពាក្យស្នើសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិមួយចំនួនទៀត ក្នុងនោះអ្នកសារព័ត៌មានជាតិ ចំនួន ៧៨ នាក់ ស្ត្រី ចំនួន ៩ នាក់ មកពី ១៦ អង្គភាព និងអ្នកសារព័ត៌មានអន្តរជាតិចំនួន ៩ នាក់ ស្ត្រី ចំនួន ២ នាក់ មកពី ៣ អង្គភាព។

គំរូពាក្យសុំ និងបែបបទសម្រាប់សុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិមានផ្តល់ជូនដោយឥតគិតថ្លៃ ឬអាចទាញយកពីគេហទំព័រ គ.ជ.ប ( www.nec.gov.kh ) និងអាចដាក់ពាក្យដោយផ្ទាល់នៅទីស្តីការ គ.ជ.ប ( ជាន់ទី៨ បន្ទប់ B ) ឬអាចផ្ញើតាមរយៈអ៊ីម៉ែល: info@nec.gov.kh ឬតេឡេក្រាម ( ០៩៣ ៨០២ ៧៣៤ )។ ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ ចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ និងអ្នកសារព័ត៌មានអន្តរជាតិ ចាប់ផ្តើមពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣៕

---

# វគ្គបណ្តុះបណ្តាលជូនមន្ត្រី គ.ជ.ប និងភាគីពាក់ព័ន្ធ ស្តីពី "ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត" ត្រូវបានបិទបញ្ចប់

វគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃ ស្តីពី "**ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត**" សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ជូនដល់ប្រធានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប) ប្រធានលេខាធិការដ្ឋាននៃ គជ.ខប សមាជិក គជ.ខប មួយចំនួន ដែលជាប្រធានផ្នែកអប់រំ ព័ត៌មាន

និងទំនាក់ទំនងសាធារណៈ ប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត និងប្រធានផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេស មន្ត្រី គ.ជ.ប តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តំណាងក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវបានបិទបញ្ចប់នារសៀលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ (NIE) រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនេះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍ថា ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងមានការទទួលស្គាល់ពីភាគីពាក់ព័ន្ធ គ.ជ.ប បានកសាងប្រតិទិន និងផែនការមេ សម្រាប់ជាត្រីវិស័យតម្រង់ទិសក្នុងការអនុវត្តការងារតាមដំណាក់កាល ព្រមទាំងបានអនុម័តបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលជាឯកសារគតិយុត្តដ៏សំខាន់មួយសម្រាប់ការអនុវត្តការងារបច្ចេកទេសជាក់ស្តែង។ ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ត្រូវបានរៀបចំ និងកែសម្រួលដោយផ្អែកលើបទពិសោធន៍កន្លងមក និងបន្ថែមបទប្បញ្ញត្តិមួយចំនួនឱ្យស្របនឹងសភាពការណ៍បច្ចុប្បន្ន រួមនឹងគោលការណ៍ទំនើបកម្មដំណើរការបោះឆ្នោត



សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល



ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប

ដែល គ.ជ.ប បានដាក់ឱ្យដំណើរការ និងទទួលបានជោគជ័យកាលពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដើម្បីជាជំនួយដល់ការរៀបចំ និងការគ្រប់គ្រងការបោះឆ្នោតឱ្យកាន់តែល្អប្រសើរ មានតម្លាភាព និងមានសុក្រឹតភាពថែមមួយកម្រិតទៀត ហើយដើម្បីជំរុញឱ្យការបោះឆ្នោតអាចប្រព្រឹត្តទៅដោយជោគជ័យបាន ក្រៅពីការកសាងលិខិតបទដ្ឋានគតិយុត្តដែលមានលក្ខណៈល្អប្រសើរ និងគ្រប់ជ្រុងជ្រោយហើយនោះ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀត ឱ្យមានការយល់ដឹងច្បាស់លាស់អំពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត គឺជាកត្តាសំខាន់ដែល គ.ជ.ប ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់ ជាក់ស្តែងដូចជាការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃនេះ ជាឧទាហរណ៍ស្រាប់។ ឯកឧត្តមបានបន្ថែមទៀតថា វគ្គបណ្តុះបណ្តាលលើកនេះ មានលក្ខណៈពិសេស និងខុសប្លែកពីវគ្គបណ្តុះបណ្តាលមុនៗ ដោយយើងធ្វើការបណ្តុះបណ្តាលលើបទបញ្ជា និងនីតិវិធី ទាំងផ្នែកទ្រឹស្តី ទាំងការអនុវត្តជាក់ស្តែង ជាពិសេស គឺការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាថ្មីៗ ដែល គ.ជ.ប ទើបបានធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យដំណើរការ ដើម្បីជាជំនួយដល់មន្ត្រីបោះឆ្នោត ដែលរួមមានជាអាទិ៍ ប្រព័ន្ធគ្រប់គ្រងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត កម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និងកម្មវិធីគ្រប់គ្រងសំណុំរឿង និងរបាយការណ៍ពាក់ព័ន្ធនឹងពាក្យបណ្តឹង។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានរំលឹកអំពីដំណាក់កាលចុះ-

បញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ទើបតែបានបញ្ចប់ទៅថ្មីៗនេះ ដោយក្នុងរយៈពេល ១៥ ថ្ងៃនៃការទទួលពាក្យសុំចុះបញ្ជីនៅ គ.ជ.ប មានគណបក្សនយោបាយចំនួន ២០ បានដាក់ពាក្យសុំចុះបញ្ជីតាមទម្រង់បែបបទកំណត់ដោយ គ.ជ.ប ហើយជាលទ្ធផល គ.ជ.ប បានសម្រេចទទួលស្គាល់ និងចុះបញ្ជីជាផ្លូវការជូនគណបក្សនយោបាយចំនួន ១៨ ដើម្បីចូលរួមប្រកួតប្រជែងក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ លើកលែងតែគណបក្សនយោបាយចំនួន ២ គឺគណបក្ស ភ្លើងទៀន និងគណបក្សមហាសាមគ្គីជាតិខ្មែរ ដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធការសុំចុះបញ្ជី ដោយសារសាមីគណបក្សមិនបានភ្ជាប់ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម ដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅការិយាល័យច្រកចេញចូលតែមួយ ឱ្យបានត្រឹមត្រូវស្របតាមកថាខណ្ឌទី២ និងចំណុចទី១ ក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ។ ហើយតំណាងគណបក្ស ទាំង ២ បានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ និងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបដិសេធចោលដោយខុសនឹងគតិច្បាប់។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ក៏បានជម្រាបជូនអំពីនីតិវិធីនៃការឃោសនាបោះឆ្នោត ក្រមសីលធម៌ និងគោលការណ៍ស្តីពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាធរមានផ្សេងៗទៀតដែលពាក់ព័ន្ធ និងបានជម្រាបជូនអំពីការបំពេញភារកិច្ច



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមិនត្រូវចូលរួមធ្វើសកម្មភាពឃោ-សនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយឡើយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។

ក្នុងឱកាសនោះដែរ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជម្រាបជូនបន្តទៀតថា ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ និងមានអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព។ ក្នុងករណីប្រជាពលរដ្ឋ ពុំទាន់មាន អ.ខ ឬមាន អ.ខ ប៉ុន្តែបានអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវប្រជាពលរដ្ឋអាចទៅបំពេញបែបបទស្នើសុំឯកសារបញ្ជាក់អត្ត-សញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) នៅទីស្នាក់ការគណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) នៃឃុំសង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដើម្បីយកទៅសុំការបញ្ជាក់ផ្តល់សុពលភាពពីអាជ្ញាធរឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ត្រៀមឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ហើយប្រសិនបើប្រជាពលរដ្ឋពុំមាន អ.ខ ដែលមានសុពលភាពនោះទេ សូមរួសរាន់ទៅទីស្នាក់ការ គឃ.សប ដើម្បីបំពេញបែបបទស្នើសុំឯ.អ ដោយឥតគិតថ្លៃ និងទាន់ពេល

វេលា ស្របតាមកាលបរិច្ឆេទដែលកំណត់ដោយ គ.ជ.ប។ ផ្អែកតាមប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត គឺមានរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

មុននឹងប្រកាសបិទបញ្ចប់វគ្គបណ្តុះបណ្តាលនេះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប ក៏បានណែនាំដល់ប្រធាន គធ.ខប ប្រធាន លគធ.ខប សមាជិក គធ.ខប និងគ្រូបង្គោលនៃ គ.ជ.ប ទាំងអស់ ត្រូវត្រៀមរៀបចំកិច្ចតែងការបង្រៀន សម្ភារឧបទេស និងត្រៀមលក្ខណៈដើម្បីធ្វើការបណ្តុះបណ្តាលបន្តនៅតាមរាជធានី ខេត្តនីមួយៗ ជូនដល់មន្ត្រីគធ.ខប តំណាងគណបក្សនយោបាយ តំណាងសមាគម និងអង្គការសង្កេតការណ៍បោះឆ្នោត និងភាគីពាក់ព័ន្ធផ្សេងទៀតតាមផែនការ ប្រតិទិន និងតាមសេចក្តីណែនាំស្តីពីការងារបណ្តុះបណ្តាលបន្ត និងអប់រំអ្នកបោះឆ្នោតនៅតាមរាជធានី ខេត្ត។

សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះសរុបចំនួនប្រមាណ ៣៦៧ នាក់៕

---

# គណបក្សនយោបាយ ត្រូវមានឱកាសស្មើភាពគ្នាក្នុងការផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន សម្រាប់ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ មានគណបក្សនយោបាយចំនួន ១៨ បានចូលរួមជាផ្លូវការ និងបានដាក់បញ្ជីបេក្ខជនរបស់ខ្លួន។ បន្ទាប់ពីត្រូវបាន គ.ជ.ប ទទួលស្គាល់គណបក្សទាំង ១៨ នឹងត្រូវធ្វើសកម្មភាពឃោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋអ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោតអាចជាសកម្មភាពមួយចំនួន ដូចជាការហែក្បួន ការជួបជុំ ការចែកខិត្តបណ្ណ ការចាក់មេក្រូចល័ត ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ជាដើម។

ដើម្បីធានាឱ្យការឃោសនាបោះឆ្នោតតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ប្រព្រឹត្តទៅដោយស្មើភាពសម្រាប់គ្រប់គណបក្សនយោបាយ គ.ជ.ប បានបង្កើតគណៈកម្មការមួយឈ្មោះថា គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយអំពីគោលនយោបាយរបស់គណបក្សនយោបាយ ហៅកាត់ថា "គណៈកម្មការសម្របសម្រួល"។

យោងតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងសេចក្តីសម្រេចលេខ ១២៤ គ.ជ.ប.ស.ស.រ ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គណៈកម្មការនេះ ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍សម្រាប់ការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ជូនគ្រប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោត។ តាមរយៈគោលការណ៍ដែលបានដាក់ចេញ កម្មវិធីស្មើភាពចែកចេញជា ៣ផ្នែក គឺទី១ កម្មវិធីតុមូលដែលគ្រប់គណបក្សនយោបាយត្រូវចូលរួមបង្ហាញនូវគោលនយោបាយរបស់ខ្លួនតាមប្រធានបទដែលគណៈកម្មការសម្របសម្រួលបានដាក់ជូន ហើយកម្មវិធីនេះត្រូវថតទុកជាមុន និងត្រូវចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ។ ទី២ កម្មវិធីស្ប៉ត



ឯកឧត្តម ម៉ុក ដារ៉ា អគ្គលេខាធិការរង គ.ជ.ប

គណបក្សនយោបាយ ដែលគណបក្សទាំងអស់ត្រូវផលិតស្ប៉ត ជាវីដេអូ និងសំឡេង ដែលមានលក្ខណៈបច្ចេកទេស និងរយៈពេល កំណត់ដោយ គ.ជ.ប សម្រាប់ចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍ របស់រដ្ឋ។ ទី៣ ការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយអត្ថបទ ឃោសនា ដែលគណបក្សទាំងអស់ត្រូវរៀបចំអត្ថបទស្តីពីគោល-នយោបាយរបស់ខ្លួន ចំនួនពីរច្បាប់ ក្នុងមួយច្បាប់មាន ១ ទំព័រ សម្រាប់ចុះផ្សាយក្នុងព្រឹត្តិបត្រស្តីពីគោលនយោបាយរបស់ គណបក្សនយោបាយ បោះពុម្ពដោយ គ.ជ.ប ចំនួន ២ លេខ។

ដើម្បីឱ្យការរៀបចំ និងការផ្សព្វផ្សាយកម្មវិធីស្មើភាព ឬ/និងសមធម៌ ប្រព្រឹត្តទៅដោយរលូនល្អ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ កន្លងទៅនេះ គណៈកម្មការសម្របសម្រួល ដឹកនាំ ដោយឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង គ.ជ.ប និងជា ប្រធានគណៈកម្មការសម្របសម្រួល បានជួបប្រជុំជាមួយតំណាង មកពីគ្រប់គណបក្សនយោបាយ។ កិច្ចប្រជុំធ្វើឡើងនៅទីស្តីការ គ.ជ.ប ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលការណ៍ក្នុង ការរៀបចំកម្មវិធីនេះ ក្នុងគោលដៅឱ្យគ្រប់គណបក្សនយោបាយ ផ្តល់កិច្ចសហការផង និងបានត្រៀមខ្លួនជាមុនផង។ កិច្ចប្រជុំ នៅថ្ងៃនោះ ក៏បានរៀបចំការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខ-រៀងមុនក្រោយនៃការចាក់ផ្សាយ និងចុះផ្សាយកម្មវិធីនយោបាយ របស់គណបក្សនយោបាយតាមវិទ្យុ ទូរទស្សន៍របស់រដ្ឋ និងព្រឹត្តិបត្រ ស្តីពីគោលនយោបាយរបស់គណបក្សនយោបាយ ដែលបោះពុម្ព ផ្សាយដោយ គ.ជ.ប ផងដែរ។

ដោយឡែក ក្នុងគោលដៅធានាឱ្យគ្រប់គណបក្សនយោ-បាយមានឱកាសដោយស្មើភាពគ្នាក្នុងការផ្សព្វផ្សាយគោល-នយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់ឯកជន ក្នុងអំឡុង ពេលនៃការឃោសនាបោះឆ្នោត គណៈកម្មការសម្របសម្រួល ក៏បានដាក់ចេញនូវគោលការណ៍ស្តីពីការលក់ ឬជួលម៉ោងផ្សាយ របស់ប្រព័ន្ធផ្សព្វផ្សាយឯកជនជូនគ្រប់គណបក្សនយោបាយ។ គោលការណ៍នេះត្រូវអនុវត្តចំពោះគ្រប់ប្រព័ន្ធផ្សព្វផ្សាយឯកជន ដែលមានបំណងលក់ ឬជួលម៉ោងផ្សាយរបស់ខ្លួនជូនគណបក្ស នយោបាយទាំងអស់ក្នុងពេលឃោសនាបោះឆ្នោតប៉ុណ្ណោះ។ ដូចនេះប្រព័ន្ធផ្សព្វផ្សាយឯកជនដែលមានបំណងលក់ ឬដាក់ ជួលម៉ោងផ្សាយរបស់ខ្លួន ត្រូវតែធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវចំនួននាទី ឬចំនួនម៉ោង និងតម្លៃ ដែលខ្លួនត្រូវលក់ ជូនដល់ គ្រប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោត។ មានន័យ ថា ប្រព័ន្ធផ្សព្វផ្សាយឯកជន ត្រូវយកម៉ោងផ្សាយសរុប ដែលខ្លួន ត្រូវលក់ ចែកនឹងចំនួនគណបក្សទាំងអស់ដែលចូលរួមក្នុងការ បោះឆ្នោត នឹងឃើញម៉ោង ឬនាទី ដែលត្រូវលក់ជូនគណបក្ស នយោបាយនីមួយៗ។ គណបក្សនយោបាយនីមួយៗមានសិទ្ធិ ទិញ ឬជួលម៉ោងផ្សាយនោះក្នុងតម្លៃដូចៗគ្នា ដោយគោរពតាម លំដាប់មុន ក្រោយ។ ប៉ុន្តែក្នុងករណីគណបក្សនយោបាយមួយ ឬច្រើនពុំបានទិញម៉ោងផ្សាយ ប្រព័ន្ធផ្សព្វផ្សាយឯកជននោះ មានសិទ្ធិយកម៉ោងផ្សាយដែលនៅសល់ ទៅបែងចែកស្មើៗគ្នា សម្រាប់លក់ជូនគណបក្សនយោបាយ ដែលបានទិញម៉ោងផ្សាយ រួចហើយ ប៉ុន្តែការលក់ជូនបន្ថែមនេះ មិនត្រូវមានរយៈពេលច្រើន ជាង ៣ ដង នៃម៉ោងផ្សាយគោល ដែលគណបក្សបានទិញ នោះទេ។



តំណាងគណបក្សនយោបាយចូលរួមក្នុងកិច្ចប្រជុំ

គោលការណ៍នេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជូនដល់គ្រប់ប្រព័ន្ធផ្សព្វផ្សាយឯកជន ដោយគណៈកម្មការសម្របសម្រួល កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ បានជួបប្រជុំជាមួយតំណាងមកពីប្រព័ន្ធផ្សព្វផ្សាយឯកជននានា និងបានជម្រាបជូនពួកគាត់រួចហើយ។ ឆ្លើយតបទៅនឹងការដាក់ចេញនូវគោលការណ៍នេះ តំណាងប្រព័ន្ធផ្សព្វផ្សាយឯកជនទាំងនោះ ក៏បានឯកភាព និងសន្យាគោរពឱ្យបានត្រឹមត្រូវ ដើម្បីធានាថា ពួកគេបានរួមចំណែកជាមួយ គ.ជ.ប ក្នុងការរៀបចំចាត់ចែងការបោះឆ្នោត ឱ្យប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

សូមជម្រាបជូនថា ការឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣



សកម្មភាពក្នុងកិច្ចប្រជុំ

នេះ មានរយៈពេល ២១ ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ (ថ្ងៃចុងក្រោយ)។ គ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤ ម៉ោង មុនថ្ងៃបោះឆ្នោត៕

---

# គ.ជ.ប អំពាវនាវឱ្យបញ្ឈប់សកម្មភាពឃោសនាក្នុងចេតនា មិនឱ្យប្រជាពលរដ្ឋទៅបោះឆ្នោត ឬឱ្យគូសសន្លឹកឆ្នោតចោល

តាមការកត់សម្គាល់ មួយរយៈចុងក្រោយនេះ មានជនមួយចំនួន បានធ្វើយុទ្ធនាការតាមរយៈខិត្តបណ្ណ រូបភាព ឬស្ប៉តឃោសនានានាតាមបណ្តាញព័ត៌មានសង្គម ដែលអំពាវនាវមិនឱ្យប្រជាពលរដ្ឋទៅបោះឆ្នោត ឬគូសបំផ្លាញសន្លឹកឆ្នោត ដោយហេតុថាពុំមានវត្តមានគណបក្ស ភ្លើងទៀន ចូលរួមក្នុងការបោះឆ្នោត។

តាមរយៈសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ក្រុមប្រតិកម្មព័ត៌មាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអំពាវនាវឱ្យបញ្ឈប់សកម្មភាពទាំងនេះជាបន្ទាន់ ហើយព្រមាននឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់បំផុត ដោយចាត់ទុកយុទ្ធនាការនេះជាសកម្មភាពខុសច្បាប់ និងប្រាសចាកទៅនឹងព្រះរាជសារអំពាវនាវឱ្យទៅបោះឆ្នោតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១៤២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលចែងថា ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយ គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

សេចក្តីប្រកាសព័ត៌មានដដែលបានបញ្ជាក់ទៀតថា គ.ជ.ប កំពុងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ យ៉ាងរលូន ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់បោះឆ្នោត។ ការដែល គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្ស ភ្លើងទៀន ក៏ដូចជា

គណបក្សមហាសាមគ្គីជាតិខ្មែរ គឺជាការអនុវត្តច្បាប់ ហើយសូមជម្រាបថា គ.ជ.ប គឺជាស្ថាប័នបច្ចេកទេស និងអនុវត្តច្បាប់ ដោយ គ.ជ.ប បានអនុវត្តដោយស្មើភាព និងគ្មានការរើសអើងចំពោះគ្រប់គណបក្សនយោបាយ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នឹងត្រូវធ្វើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ គ.ជ.ប ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ ទៅចូលរួមបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ព្រោះជាឱកាសតែមួយគត់ រៀងរាល់ប្រាំឆ្នាំម្តង ដើម្បីជ្រើសរើសថ្នាក់ដឹកនាំរបស់យើង និងជាប្រយោជន៍សម្រាប់អនាគតយើងផ្ទាល់៕

# គ.ជ.ប នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមការងារក្នុងក្របខណ្ឌបោះឆ្នោត នៃប្រទេសនិយាយភាសាបារាំង ដោយស្មើមុខ ស្មើមាត់

ក្នុងឱកាសវិលត្រឡប់មកមាតុភូមិវិញ កាលពីល្ងាចថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឌឹម សុវណ្ណារុំ** សមាជិក គ.ជ.ប និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានថ្លែងក្នុងសន្និសីទសារព័ត៌មាននៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ថា គ.ជ.ប បានចូលរួមប្រជុំ ក្នុងក្របខណ្ឌស្ថាប័នបោះឆ្នោតនៃប្រទេសនិយាយភាសាបារាំង ដោយស្មើមុខ ស្មើមាត់។



**ឯកឧត្តម ឌឹម សុវណ្ណារុំ សមាជិក គ.ជ.ប និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប**

សូមជម្រាបជូនថា គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោតកម្ពុជា បានចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ចំនួន ២ នោះគឺ សិក្ខាសាលាអន្តរជាតិលើកទី១១ ស្តីពី **"បែបបទនៃការបោះឆ្នោតដើម្បីសម្រួលការចូលរួមរបស់ម្ចាស់ឆ្នោត និងការរក្សាទំនុកចិត្ត"** និងមហាសន្និបាតលើកទី១០ របស់បណ្តាញពង្រឹងសមត្ថភាពរៀបចំការបោះឆ្នោតនៃប្រទេសនិយាយភាសាបារាំង ហៅកាត់ថា RECEF ដែលរៀបចំឡើងនៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

វត្តមាននៅក្នុងឱកាសនោះ ក៏មានស្ថាប័នធំៗ ដូចជា៖

- អង្គការអន្តរជាតិនៃប្រទេសនិយាយភាសាបារាំង (OIF) ដែលមានសមាជិក ៨៨ ប្រទេស និងមានអ្នកនិយាយភាសាបារាំងសរុបក្នុងលោកចំនួន ៣១០ លាននាក់
- អង្គការអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យដែលជួយក្នុងការងារបោះឆ្នោត (IDEA)
- មជ្ឈមណ្ឌលអឺរ៉ុបគាំទ្រការបោះឆ្នោត (eces)
- សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិចដែលមានសមាជិក ១៥ ប្រទេស ដែលហៅកាត់ថា CEDEAO



**សកម្មភាពក្នុងសន្និសីទសារព័ត៌មាន**

ក្នុងកិច្ចការបោះឆ្នោត ជាដើម។

ចំពោះសិក្ខាសាលាអន្តរជាតិ កិច្ចពិភាក្សាបានផ្តោតទៅលើរបៀបបោះឆ្នោត ឬការបោះឆ្នោតរបៀបយ៉ាងម៉េចដើម្បីទាក់ទាញអ្នកបោះឆ្នោតចូលរួមបោះឆ្នោតឱ្យមានចំនួនច្រើន ដោយបង្ហាញពីការបោះឆ្នោតជាច្រើនទម្រង់ គឺការបោះឆ្នោតមុនពេលកំណត់ ការបោះឆ្នោតដោយផ្ទាល់នៅបន្ទប់សម្ងាត់ ការបោះឆ្នោតតាមរយៈសំបុត្រ ការបោះឆ្នោតជំនួសឱ្យគេ និងការចល័តការិយាល័យបោះឆ្នោតទៅកាន់ផ្ទះអ្នកបោះឆ្នោត ជាដើម។

បើទោះជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ រួមទាំងការគិតគូរដល់អ្នកបោះឆ្នោតដែលមានពិការភាព អ្នកបោះឆ្នោតអន្តោប្រវេសន៍ អ្នករស់នៅទីដាច់ស្រយាល និងអ្នកបោះឆ្នោតជាជនជាតិភាគតិច អត្រាអ្នកបោះឆ្នោតនៅប្រទេសខ្លះមានការកើនឡើង ប៉ុន្តែនៅប្រទេសខ្លះទៀតមានការថយចុះ ដូចជាការបោះឆ្នោតចុងក្រោយនេះ នៅប្រទេសបារាំង ជាពិសេសការបោះឆ្នោតប្រធានាធិបតី រហូតមានការលើកជាសំណួរទៅកាន់លោកស្រី Mariam PONTONI អនុប្រធានការិយាល័យបោះឆ្នោតនយោបាយនៃក្រសួងមហាផ្ទៃ និងដែនដីឯនាយសមុទ្របារាំង អំពីភាពស្របច្បាប់នៃការជាប់ឆ្នោត។ ចំពោះចំណុចនេះ លោកស្រីបានឆ្លើយថា គឺមិនប៉ះពាល់ដល់ភាពស្របច្បាប់នៃបេក្ខជនជាប់ឆ្នោតទេ គឺគេគិតទៅលើសន្លឹកឆ្នោត ឬសំឡេងឆ្នោតដែលបានបញ្ចេញទទួលស្គាល់បេក្ខជនជាក់ស្តែង មិនមែនទៅលើអត្រានៃអ្នកបោះឆ្នោតតិច ឬច្រើននោះទេ។

ជាងនេះទៀត ឯកឧត្តម **ឌឹម សុវណ្ណារុំ** ក៏បានចាប់អារម្មណ៍ថា ការដូរ ឬបន្ថែមរបៀបបោះឆ្នោត ឬទម្រង់បោះឆ្នោត គឺត្រូវចាប់ផ្តើមជាដំបូង ដោយគិតពីក្របខណ្ឌច្បាប់ជាមុនសិន ហើយបើតាមប្រសាសន៍ ឯកឧត្តម **ឌឹម សុវណ្ណារុំ** លោក **Sébastien Audebert** ប្រធានការិយាល័យបោះឆ្នោតនយោបាយនៃក្រសួងមហាផ្ទៃ និងដែនដីឯនាយសមុទ្របារាំង លោកបានសង្កត់ធ្ងន់ថា រឿងបោះឆ្នោតនេះ បើចង់កែអ្វីមួយ ត្រូវពិនិត្យច្បាប់ជាមុនសិន រួចត្រូវឆ្លងសភា ឆ្លងក្រុមប្រឹក្សាធម្មនុញ្ញ និងជាពិសេសឆ្លងម្ចាស់ឆ្នោត មុននឹងស្ថាប័នបោះឆ្នោតដាក់ឱ្យអនុវត្ត។

ក្នុងន័យនេះ ជាក់ស្តែងនៅកម្ពុជា ច្បាប់បោះឆ្នោតចែងថា ដើម្បីអាចបោះឆ្នោតបាន ម្ចាស់ឆ្នោតត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយនៅពេលបោះឆ្នោតត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ហើយការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតត្រូវប្រព្រឹត្តទៅនៅឃុំសង្កាត់ដែលពួកគាត់រស់នៅរីឯការបោះឆ្នោត គឺមានតែមួយប្រភេទ គឺអ្នកបោះឆ្នោតត្រូវទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតដោយផ្ទាល់ ហើយតាមបទពិសោធន៍នៅកម្ពុជា មិនមែនជាចំណោទទេ ដោយអត្រានៃអ្នកបោះឆ្នោតមានចំនួនច្រើន សម្រាប់ការបោះឆ្នោតសកលមួយលើកៗ។

ចំពោះមហាសន្និបាតវិញ ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានអបអរសាទរដោយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ត្រូវបានកត់ចំណាំថា គ.ជ.ប នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន RECEF បោះឆ្នោតគាំទ្រ ជាសមាជិកពេញសិទ្ធិជាឯកច្ឆន្ទដោយកុងសង់ស៊ីសនៃសមាជិកចូលរួមទាំងអស់ដែលរួមមានប្រទេសជាសមាជិកចំនួន ២២ និងដៃគូ RECEF ចំនួន ៣ គឺអង្គការអន្តរជាតិនៃប្រទេសនិយាយភាសាបារាំង (OIF) មជ្ឈមណ្ឌលអឺរ៉ុបគាំទ្រការបោះឆ្នោត (eces) និងអង្គការអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យដែលជួយក្នុងការងារបោះឆ្នោត (IDEA)។

គ.ជ.ប កម្ពុជា និង គ.ជ.ប នៃសមាជិក RECEF ដទៃទៀត នឹងមានឱកាសលើកកម្ពស់សមត្ថភាពរៀបចំការបោះឆ្នោតស្របតាមការវិវត្តនៃសកលភាវូបនីយកម្ម ដោយនៅខែធ្នូ ឆ្នាំ២០២៣ នេះ នឹងមានការបណ្តុះបណ្តាលស្ត្រីដែលចេះនិយាយភាសាបារាំងស្តីពី ភាពជាអ្នកដឹកនាំក្នុងកិច្ចការនយោបាយនៅប្រទេស Cap Vert ដែលជាម្ចាស់ផ្ទះ ហើយប្រទេសជាសមាជិក RECEF ត្រូវបញ្ជូនតំណាងរបស់ខ្លួនម្នាក់ដែលជាស្ត្រី។

ឯកឧត្តម **ឌឹម សុវណ្ណារុំ** បានអះអាងជាចុងក្រោយថា RECEF ដែលមានសមាជិក ៣៤ ប្រទេស និងសហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច (CEDEAO) ដែលមានសមាជិក ១៥ ប្រទេស នឹងបញ្ជូនថ្នាក់ដឹកនាំកំពូលរបស់ខ្លួន មកចូលរួមសង្កេតការណ៍បោះឆ្នោតនៅកម្ពុជា នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ៕

# គ.ជ.ប រៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតលើសន្លឹកឆ្នោត

នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ពិធីនេះបានប្រព្រឹត្តទៅក្រោមព្រះវត្តមានសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយ និងសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **កិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងពិធីនោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ថ្ងៃនេះជាទិវា ដ៏មហោឡារិកដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតលើសន្លឹកឆ្នោត ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ខែកក្កដា ឆ្នាំ២០២៣។



**សកម្មភាពក្នុងពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយលើសន្លឹកឆ្នោត**



**ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប**

ឯកឧត្តមបានបន្តថា ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ បាននិងកំពុងប្រព្រឹត្តទៅយ៉ាងសកម្មតាមផែនការមេ និងប្រតិទិនដែលបានគ្រោងទុក។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផលិតសន្លឹកឆ្នោតតាមមណ្ឌលនីមួយៗ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនៅក្នុងសន្លឹកឆ្នោតទាំងនោះ ត្រូវការជាចាំបាច់នូវលំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលនឹងត្រូវកំណត់ជាលេខរៀងរបស់គណបក្សនយោបាយនីមួយៗនៅលើសន្លឹកឆ្នោតសម្រាប់មណ្ឌលទាំង ២៥ នៅទូទាំងប្រទេស។ ដើម្បីធានាបាននូវភាពយុត្តិធម៌ និងតម្លាភាព ក្នុងការកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំពិធីនេះឡើង ដោយបានយាងសម្តេចព្រះសង្ឃរាជទាំងពីរគណៈធ្វើជាព្រះរាជាធិបតី និងប្រោសព្រះរាជទានចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍បន្តទៀតថា ពិធីចាប់ឆ្នោតបានប្រព្រឹត្តទៅតាមនីតិវិធីមួយត្រឹមត្រូវ ច្បាស់លាស់ យុត្តិធម៌ និងតម្លាភាព ក្រោមព្រះរាជាធិបតីភាពសម្តេចព្រះសង្ឃរាជ



**(រូបកណ្តាល) ឯកឧត្តម ហង្ស ពុទ្ធា សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប**

ទាំងពីរគណៈ និងមានការសាទរពីគ្រប់មជ្ឈដ្ឋាន។ ហើយលទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត មានអត្ថន័យសំខាន់ណាស់សម្រាប់គណបក្សនយោបាយទាំងអស់ដែលឈរឈ្មោះបោះឆ្នោត និងជួយបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយពាក់ព័ន្ធក្នុងការឃោសនាបោះឆ្នោត ការបោះឆ្នោត និងជួយឱ្យអ្នកបោះឆ្នោតអាចស្គាល់បានដោយងាយស្រួលនូវគណបក្សនយោបាយដែលគាត់ស្រឡាញ់ពេញចិត្ត។

បន្ទាប់ពីបញ្ចប់ពិធីចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប បានជម្រាបជូនដល់អ្នកសារព័ត៌មានថា លទ្ធផលនៃការចាប់ឆ្នោតដែលមាន ១៨ គណបក្សនយោបាយ នេះ គ.ជ.ប នឹងយកទៅរៀបចំបោះពុម្ពនៅលើសន្លឹកឆ្នោត។

ពាក់ព័ន្ធនឹងការចូលរួមរបស់គណបក្សនយោបាយក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមាន ២ គណបក្សនយោបាយត្រូវបាន គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដោយមូលហេតុថាគណបក្សទាំងពីរនោះមិនបានភ្ជាប់មកជាមួយនូវប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃដែលមានបញ្ជាក់នីត្យានុកូលកម្ម ហើយក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានបដិសេធចោលដោយខុសនឹងគតិច្បាប់ ឯកឧត្តម **ហង្ស ពុទ្ធា** បានបញ្ជាក់បន្ថែមថា នោះគឺជាកំហុសរបស់សាមីគណបក្សនយោបាយ ពីព្រោះគណបក្សនយោបាយពុំមានឯកសារច្បាប់ដើម ដើម្បីធ្វើនីត្យានុកូលកម្ម ប៉ុន្តែត្រូវផ្ទៀងផ្ទាត់ជាមួយបញ្ជីឈ្មោះគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ។

ដើម្បីឆ្លើយតបទៅនឹងមតិមួយចំនួនតូចដែលបានលើកឡើងថា ហេតុអ្វីបានជាគណបក្ស ភ្លើងទៀន អាចចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ កន្លងមកបាន ឯកឧត្តម **ហង្ស ពុទ្ធា** បានគូសបញ្ជាក់ថាការបោះឆ្នោតនោះគឺជាការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មាន ១.៦៥២ ឃុំ សង្កាត់ ជាមណ្ឌលឈរឈ្មោះបោះឆ្នោត។ ដូចនេះ អាចតម្រូវឱ្យគណបក្សនយោបាយធ្វើនីត្យានុកូលកម្ម ១.៦៥២ ច្បាប់ សម្រាប់ឈរឈ្មោះបោះឆ្នោត។ ហេតុនេះហើយទើប គ.ជ.ប បានសម្រេចឱ្យប្រើតែឯកសារកូពីច្បាប់ដើមដោយមិនធ្វើនីត្យានុកូលកម្ម។

ឯកឧត្តម **ហង្ស ពុទ្ធា** បានមានប្រសាសន៍បន្តទៀតថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺជាការបោះឆ្នោតថ្នាក់ជាតិ គ.ជ.ប អនុវត្តតាមមាត្រា ២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយត្រូវបានអនុវត្តតាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ មកម្ល៉េះ។ រីឯការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីនៅ គ.ជ.ប ហើយតម្រូវឱ្យគណបក្សនយោបាយធ្វើនីត្យានុកូលកម្មតែមួយច្បាប់ទេ។ ប៉ុន្តែដោយសារនៅឆ្នាំ២០១៨ មានគណបក្សនយោបាយខ្លះមិនបានចូលរួមការបោះឆ្នោត និងមិនបានតាមដានស្វែងយល់ឱ្យបានដិតដល់ ដែលជាហេតុមិនយល់ពីនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។


រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល (Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News